**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣២៧
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥
**សាលដីកា**
លេខ:២៨៩
ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ………… ជាប្រធាន
២-លោក ………….. ជាចៅក្រម
៣-លោក ………….. ជាចៅក្រមរបាយការណ៍
៤-លោក ……………. ជាចៅក្រម
៥-លោក …………….. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោកស្រី ……………

**តំណាងមហាអយ្យការ**

-ឯកឧត្តម ………… ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៦៦(ឈ)ចុះថ្ងៃទី១១ខែឧសភា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦១៧ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះបគស(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស ជាតិខ្មែរ មានទីលំនៅផ្ទះលេខ២០៦ ផ្លូវលេខ១៨៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោក…………,

ចុងចម្លើយឈ្មោះងយរ(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៦ឆ្នាំជាតិខ្មែរ មានទីលំនៅផ្ទះលេខ១៨៥ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោកកែក ឃី និងលោកសែម ចិន្តា .

កម្មវត្ថុបណ្តឹងៈ - ប្តឹងសុំឱ្យអនុវត្តកាតព្វកិច្ចបង់ប្រាក់

-ប្តឹងទាមទារប្រាក់ថ្លៃឈ្នួលសណ្ឋាគារ

-ប្តឹងសុំរំលាយកិច្ចសន្យាជួលសណ្ឋាគារ

បានឃើញបណ្តឹងសាទុក្ខលេខ២៥៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ របស់មេធាវីឈ្មោះ......... តំណាងឱ្យឈ្មោះងយរ ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៦៦(ឈ)ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣២៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់លាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៤-១១-២០០៣ និងចុះថ្ងៃទី០៤-១២-២០០៣ របស់ដើមចោទលោក............ មេធាវីតំណាងឱ្យលោកបគសបញ្ជាក់ថា ខ្លួនសុំប្តឹងឱ្យអនុវត្តកាតព្វកិច្ចបង់ប្រាក់សុំទាមទារប្រាក់ថ្លៃឈ្នួលសណ្ឋាគារ និងសុំរំលាយកិច្ចសន្យាជួលសណ្ឋាគារចុះថ្ងៃទី១៩-១២-២០០១ ដោយសំអាងហេតុថា : ចុងចម្លើយបានចុះកិច្ចសន្យាជួលសណ្ឋាគារចុះថ្ងៃទី១៩-១២-២០០១ ហើយភាគីចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្លៃឈ្នួលសណ្ឋាគារឱ្យគ្រប់ចំនួននិងទៀងទាត់តាមពេលវេលាកំណត់ក្នុងកិច្ចសន្យាជួលសណ្ឋាគារឡើយ ហើយថែមទាំងពន្យាពេលបង់ប្រាក់ពីមួយខែទៅមួយខែ ព្រមទាំងយកសណ្ឋាគារនេះទៅជួលឱ្យភាគីទីបីបន្តទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៤(ច) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៤-១១-២០០៣ និងពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី០៤-១២-២០០៣ របស់តំណាងដើមចោទ............ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់លោកបគសជូនលោកមេធាវីនូ ទេពិរិទ្ធិ ជាតំណាងតាមលិខិតចុះថ្ងៃទី៣០-១០-២០០៣ ទុកជាមានសុពលភាពតាមច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់លោកងយរ ជូនលោកមេធាវីប៉ាងសុជា ជាតំណាងតាមលិខិតចុះថ្ងៃទី២៨-១១-២០០៣ ទុកជាមានសុពលភាពតាមច្បាប់ ។

៤-រំលាយកិច្ចសន្យា ចុះថ្ងៃទី១៩-១២-២០០១ ទុកជាអសារបង់ចាប់ពីពេលនេះតទៅ ដោយដាក់កំហុសលើភាគីចុងចម្លើយ គឺលោកងឹម យូរីន ។

៥-បង្គាប់ឱ្យលោកងឹម យូរីន សងប្រាក់ទៅឱ្យលោកបគសដូចតទៅ:

ក-ប្រាក់កក់ និងប្រាក់ថ្លៃឈ្នួល គិតត្រឹមខែកុម្ភៈឆ្នាំ២០០៤ សរុបចំនួន៥២៩៣៥ដុល្លា ៥០សេន (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយសាមសិបប្រាំដុល្លាអាមេរិក និងហាសិបសេន) និងឱ្យបង់ការប្រាក់បន្ថែមទៀតចំនួន២%ក្នុងមួយខែ នៃចំនួនទឹកប្រាក់នេះ ដោយគិតពីខែកុម្ភៈ ឆ្នាំ ២០០៤ រហូតដល់ថ្ងៃអនុវត្តបាន ។

ខ/ប្រាក់ថ្លៃឈ្នួលប្រចាំខែ ក្នុងមួយខែចំនួន៦១៨០ដុល្លា (ប្រាំមួយពាន់មួយរយប៉ែតសិបដុល្លា) ព្រមទាំងឲ្យបង់ការប្រាក់ចំនួន២%ក្នុងមួយខែ គិតពីខែមីនា ឆ្នាំ២០០៤ តទៅរហូតដល់ថ្ងៃអនុវត្តបាន ។

គ/ប្រាក់ជម្ងឺចិត្ត ព្រមទាំងថ្លៃសេវាច្បាប់ផ្សេងៗចំនួន២៥០០០ដុល្លា(ពីរម៉ឺនប្រាំពាន់ដុល្លា)សំណើលើសពីនេះ ត្រូវបដិសេធចោល ។

៦-កាលបើភាគីចុងចម្លើយ ពុំព្រមអនុវត្តតាមការសម្រេចខាងលើ ត្រូវដាក់គុកបង្ខំលើរូបកាយតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៧-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧០០០៛ គឺពន្ធចុះបញ្ជី រង្វាន់ក្រឡាបញ្ជីកាហើបប្រាក់ចំនួន២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥០០០៛ សរុបចំនួន៧០០០៛ ដែលតំណាងដើមចោទលោក........... បានបង់ទុកជាស្រេច ។

កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយគឺលោកងយរ សងប្រាក់ចំនួន៧០០០៛ ទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន១%លើចំនួនទឹកប្រាក់ដែលត្រូវសងដែលប្រាក់នោះបង់ចូលថវិការដ្ឋចំនួន ៨០% និងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០% ។

៨-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី០៥-៣-២០០៤ របស់ឈ្មោះប៉ាង សុជា តំណាងឱ្យលោកងឹម យូរីន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៤(ច)ចុះថ្ងៃទី២០ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណី៣៩(ច)ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់លោកមេធាវីឈ្មោះប៉ាង សុជា ជាតំណាងឱ្យលោកងឹម យូរីន ចុះថ្ងៃទី០៥-៣-២០០៤ ទុកជាបានធ្វើឡើងត្រឹមត្រូវក្នុងកំឡុងច្បាប់ ។

២-តម្កល់សាលក្រមកំបាំងមុខលេខ១៤(ច) ចុះថ្ងៃទី២០-០៦-២០០៤ ទុកជាបានការពេញទាំងមូល តាមច្បាប់វាលែងតែចំនុច៥ ត្រូវបានកែប្រែដូចតទៅ :

- បង្គាប់ឱ្យលោកងឹម យូរីន សងប្រាក់ទៅឱ្យលោកបគសដូចខាងក្រោម :

ក-ប្រាក់កក់ និងប្រាក់ថ្លៃឈ្នួលគិតមកត្រឹមខែកក្កដា ឆ្នាំ២០០៤ ចំនួន៣៦.៨៧៤៥០០ (បីម៉ឺនប្រាំមួយពាន់ប្រាំបីរយចិតសិបបួនដុល្លាអាមេរិក)និងឱ្យបង់ការប្រាក់បន្ថែមចំនួន២% ក្នុងមួយខែនៃចំនួនប្រាក់ខាងលើគិតពីថ្ងៃនេះតទៅ រហូតដល់ថ្ងៃអនុវត្តបាន ។

ខ-ប្រាក់ឈ្នួលប្រចាំខែ ក្នុងមួយខែចំនួន៦១៨០ដុល្លា(ប្រាំមួយពាន់មួយរយប៉ែតសិបដុល្លា) ព្រមទាំងការប្រាក់២%ក្នុងមួយខែ នៃចំនួនប្រាក់ឈ្នួល គិតពីថ្ងៃនេះតទៅរហូតដល់ថ្ងៃអនុវត្តបាន ។

គ-ប្រាក់ជំងឺចិត្តព្រមទាំងថ្លៃសេវាច្បាប់ផ្សេងៗចំនួន១៥០០០ដុល្លា (មួយម៉ឺនប្រាំបួនពាន់ ដុល្លាអាមេរិក)បន្ថែមទៀត សំណើផ្សេងៗលើសពីនេះ ត្រូវបដិសេធចោល ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឱ្យគូភាគី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៨(ច)ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ របស់ឈ្មោះប៉ាង សុជា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៣៩(ច) ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៦(ឈ) ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១-៨-២០០៤ របស់លោកមេធាវីប៉ាងសុជា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៣៩(ច) ចុះថ្ងៃទី០៨-៨-២០០៤ របស់តុលាការក្រុងភ្នំពេញទុកជាបានការដដែល ដោយគ្រាន់តែសម្រេចកែប្រែចំណុចទី៦នៃសេចក្តីសម្រេច របស់សាលក្រមរដ្ឋប្បវេណីលេខ១៤(ច) ចុះថ្ងៃទី២០-០២-២០០៤ របស់តុលាការក្រុងភ្នំពេញដោយ សម្រេចលុបការដាក់គុកបង្ខំរូបកាយចោល និងសម្រេចរឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្តារ៉ូយ៉ាល់(STARROYALHOTEL ) ចំណុចក្រៅពីនេះរក្សាទុកជាចុះនការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍គឺៈពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣.០០០៛ ដែលឈ្មោះបគសបានបង់រួចហើយ ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៩-០៤-២០០៥ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី១១-៥-២០០៥ កំបាំងមុខគូក្តី តែទុកជាចំពោះមុខ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៥៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ របស់មេធាវីឈ្មោះគា អាវ តំណាងឱ្យឈ្មោះងយរ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៦៦(ឈ)ចុះថ្ងៃទី១១ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៦ របស់ឈ្មោះងយរ ។

បានឃើញសារណាតប ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៦ របស់ឈ្មោះបគស។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

សាលដីការដ្ឋប្បវេណីលេខ៦៦(ឈ) ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះងឹម យូរីន នាពេលសវនាការថាៈកាលពីថ្ងៃទី១៩-ខែធ្នូ ឆ្នាំ២០០១ ខ្លួនបានជួលដីនឹងសំណង់ដែលសាងសង់មិនទាន់រួចរាល់មួយកន្លែងពីលោកបគសក្នុងរយៈពេល២០ឆ្នាំ ដោយគិតពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាព្រមព្រៀង ។ ចំពោះការបង់ថ្លៃឈ្នួលគិតពីឆ្នាំ២០០២ ដល់ឆ្នាំ ២០០៣ ត្រូវឡើងថ្លៃឈ្នួល១៨០ដុល្លាអាមេរិក ក្នុង១ខែបន្ថែមទៀតជារៀងរាល់ឆ្នាំ ។

នៅពេលធ្វើកិច្ចសន្យាជួលនោះលោកបគសធ្វើការធានាអះអាងជាមួយខ្លួនថា អាគារនេះចំណាយរយៈពេលសាងសង់បន្ថែមប្រហែលរយៈពេល៦ខែ ហើយអស់ប្រាក់ប្រហែល២៥.០០០០ដុល្លាអាមេរិក តែប៉ុណ្ណោះពេលនោះខ្លួនក៏ជឿតាមគាត់ ប៉ុន្តែពេលខ្លួនសាងសង់ប្រើរយៈពេលអស់១ឆ្នាំ និងបានចំណាយដើមទុនរហូតដល់ទៅ៨០.០០០០ដុល្លាអាមេរិកឯណោះ គឺវាខុសពីអ្វីដែលលោកប៊ូ គុយសេងអះអាង ។

ខ្លួនទទួលស្គាល់ថា ខ្លួនពិតជានៅជំពាក់ប្រាក់ថ្លៃឈ្នួលអាគាររបស់លោកបគសពិតប្រាកដមែន មូលហេតុដោយសារលោកបគសផ្ទេរឈ្នួលទៅជាប្រាក់កក់ផង និងរួមផ្សំ និងអ្នកដែលបានជួលសណ្ឋាគារខ្លួន ហើយពុំបានបង់ប្រាក់មកឱ្យខ្លួនតាមកិច្ចសន្យានោះឡើយ ។

សំណូមពរ សុំឯកឧត្តមមេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់ក្រឡាបញ្ជីអានសារណារបស់ឈ្មោះបគស។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែក ឃី ជាមេធាវីការពារឱ្យចុងចម្លើយបានលើកឡើងថា : កិច្ចសន្យាដែលកូនក្តីខ្លួននិងលោកបគសធ្វើកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ គឺស្របនឹងមាត្រាទី១នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា ដោយមានការព្រមព្រៀងគ្នា ហើយគ្មានការបង្ខិតបង្ខំពីភាគីណាមួយ ។

មាត្រាទី១៩ នៃក្រឹត្យច្បាប់ស្តីពីកិច្ចសន្យាបានចែងថា : ការសុំមោឃភាពអាចប្តឹងសុំមោឃភាពនៃកិច្ចសន្យានោះ ក្នុងរយៈពេល១២ខែយ៉ាងយូរ ។ ហើយកិច្ចសន្យានេះកូនក្តីខ្លួនបានអនុវត្ត ជាហូរហែរមកហើយ ហើយក៏បានបង់ថ្លៃឈ្នួលអាគារឱ្យលោកបគសបានចំនួន២៣៥៧០០ ដុល្លាអាមេរិកផងដែរ ហើយក្រោយមកកូនក្តីខ្លួនអាក់ខានបង់ថ្លៃឈ្នួលនេះទៅវិញ គឺដោយសារលោកបគសបានឱ្យកូនក្តីខ្លួនបង់ថ្លៃឈ្នួលអាគារប្តូរទៅជាប្រាក់កវិញ ។ នេះបញ្ជាក់ថា កំហុសនេះ គឺបង្កឡើងដោយលោកបគសខ្លួនឯងផ្ទាល់តែម្តង ។

ចំណុចមួយទៀតគឺខ្លួន កែត ឃី សុំគាំទ្រតំណាងមហាអយ្យការលើកឡើងទាំងស្រុង ។

សំណូមពរ ១- សុំរក្សាកិច្ចសន្យាជួលឱ្យនៅដដែល និងសុំសងប្រាក់ដែលមិនទាន់បង់។

២-សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីសម្រេចជាថ្មីឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសែម ចិន្តា ជាមេធាវីការពារឱ្យចុងចម្លើយ បានលើកឡើងបន្ថែមថា៖

១-សុំបន្តកិច្ចសន្យាជាបន្តទៅទៀតតាមការព្រមព្រៀង

២-សុខចិត្តបង់ប្រាក់ឈ្នួលដែលនៅសល់

៣-សុំឱ្យមានការកាត់ប្រាក់ដែលបានបង់រួច ២៣៥៧០០ដុល្លាអាមេរិក ទៅក្នុងប្រាក់ដែល លោកបគសបានទាមទារទាំងអស់ ។

៤-សុំបង់ការប្រាក់៥%ក្នុង១ឆ្នាំ តាមផ្លូវច្បាប់ ។

៥-បើសិនជាលោកបគសចង់បានសណ្ឋាគារនោះទៅគ្រប់គ្រងវិញ សុំឱ្យលោកប៊ូ គុយសេង សងប្រាក់ចំនួន៨០.០០០០ ដុល្លាអាមេរិក ថ្លៃសាងសង់បន្ថែម និងការចំណាយរយៈពេលជាង ១ឆ្នាំ ក្នុងការសាងសង់បន្តពីលោក ហើយខុសពីអ្វីដែលលោកបានជានាអះអាង នៅពេលដែលធ្វើកិច្ចសន្យាជួល ។

៦-សុំឱ្យមានការលប់ចោលទាំងស្រុងនូវប្រាក់សំណងជម្ងឺចិត្តចំនួន១៩០០០ដុល្លាអាមេរិក។

**សំណូមពរៈ** សុំឱ្យក្រុមប្រឹក្សាជំនុំជំរះពិចារណាលើសាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីដោយខ្វះចន្លោះ និងសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក........... ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា ក្នុងរឿងនេះខ្លួនសូមឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីការដ្ឋប្បវេណីលេខ៦៦(ឈ) ចុះថ្ងៃទី១១-០៥-២០០៥ របស់សាលាឧទ្ធរណ៍ទាំងមូល និងសុំបដិសេធសារណាការពារចុះថ្ងៃទី០៦-០៣-២០០៦ របស់ឈ្មោះងឹម យូរីន ចោលទាំងស្រុង ពីព្រោះឈ្មោះងឹម យូរីន មានកំហុសដោយពុំបានអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ម្ចាស់បណ្តឹងសាទុក្ខ សារណារបស់ដើមចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ របស់លោក......... ជាមេធាវីតំណាងឱ្យលោកងឹម យូរីន ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលា ជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលសម្រេចរំលាយកិច្ចសន្យាជួលចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់គូភាគីចោលជាអសារបង់ ហើយបង្គាប់ភាគីលោកងឹម យូរីន មានកាតព្វកិច្ចសងប្រាក់កក់ និងប្រាក់ថ្លៃឈ្នួល ព្រមទាំងការប្រាក់២% ក្នុង១ខែ ទៅដើមចោទ គឺជាការភ័ន្តច្រឡំដោយហេតុថា :

-តាមប្រការ២នៅត្រង់ចំណុច(គ) នៃកិច្ចសន្យាជួលចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ មិនតម្រូវ ឱ្យភាគីជួល បង់ការប្រាក់ឈើប្រាក់កក់ឡើយ ហើយម្យ៉ាងទៀត តុលាការអង្គសេចក្តីក៏ពុំបានលើក បង្ហាញអំពីចំណុចនេះ នៅក្នុងផ្នែកសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួនឡើយ ។

-តុលាការអង្គសេចក្តីមិនទាន់បានពិចារណាអំពីការ្យ និងសំភារៈទាំងឡាយ ដែលភាគីជួល បានជួសជុលបន្ថែមលើសំណង់ដើម ក្រោយពេលចុះកិច្ចសន្យាក៏ដូចជាការ្យនិងសំភារៈទាំងឡាយ ដែលជាប់សិទ្ធិរបស់តតិយជន នៅឡើយទេ ពីព្រោះថា បើតាមមាត្រា២ នៅត្រង់ចំណុច(ខ) ភាគីម្ចាស់អាគារ អាចរឹបអូសយកតែសំណង់ជួលតាមលក្ខណៈដូចរូបរបស់អាគារមុនពេលចុះហត្ថលេខា ប៉ុណ្ណោះ ហើយមិនអាចរឹបអូសយកសំភារៈណាដែលភាគីជួលបានជួលពីតតិយជនមកដាក់ជាប់អាគារ ដើម្បីប្រកបអាជីវកម្មឡើយ ។

- យល់ឃើញថា ដើមចោទមិនបានចូលរួមនាសវនាការនេះទេ តែបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ហើយមេធាវីរបស់ដើមចោទ ក៏បានមកចូលរួមសវនាការនេះហើយដែរ ដូចនេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៦៦(ឈ) ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ២២៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ របស់លោក......... ជាមេធាវីតំណាងឱ្យលោកងឹម យូរីន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៦(ឈ) ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសិណំរឿងរដ្ឋប្បវេណីលេខ៣២៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកបគសបានបងផ្ញើសនៅតុលាការកំពូលចំនួន១៩.០០០៛ គឺ

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

៥-សាលដីកានេះជំនុំជំរះនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ខែកញ្ញាឆ្នាំ២០០៦ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ ។